# ក្រសួងពាណិជ្ជកម្មប្រគល់ត្រាក់ទ័រ០១ គ្រឿង ដល់កងពលតូច
# អន្តរាគមន៍លេខ១១ នៅភ្នំដីររមៀល ស្រុកជុំគីរី ខេត្តកំពត

ត្រាក់ទ័រ ០១គ្រឿងមានតំលៃ **១៩.000** ដុល្លាសហរដ្ឋអាមេរិក ដែលជាអំណោយរបស់ក្រសួងពាណិជ្ជកម្ម ត្រូវបានប្រារព្ធពិធីប្រគល់-ទទួល នៅទីបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ១១ ដែលមានទីតាំង ស្ថិតនៅ ភ្នំដីររមៀល ស្រុកជុំគីរី ខេត្តកំពត ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួម ពីឯកឧត្តម អស់លោក-លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួងពាណិជ្ជកម្ម និងនាយទាហ៊ាន-ពលទាហ៊ាន ចំណុះកងពលតូចអន្តរាគមន៍លេខ១១ យ៉ាងច្រើនកុះករ ។ ដោយឡែក លោកឧត្តមសេនីយ៍ឯក **ប្រាក់ សុវណ្ណា** មេបញ្ជាការរងកងទ័ពជើងគោក និងលោក **ហេង ឡុង** នាយកក្រុមហ៊ុន ឡុង ស្រេង ចំការកៅស៊ូ បឹង កេត ក៏មានវត្តមានចូលរួមនា ឱកាសនោះផងដែរ ។





ឯកឧត្តមឧត្តមសេនីយ៍ទោ **យឿង សុខុន** មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ១១ បានមានប្រសាសន៍សំដែងនូវការស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ ពីសំណាក់ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងលោកជំទាវ ក៏ដូចជាថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុន ឡុង ស្រេង ចំការកៅស៊ូ បឹងកេត ដែលជានិច្ចជាកាលតែង បានជួយឧបត្ថម្ភទាំងសំភារៈ ថវិការ ជាច្រើនដល់អង្គភាពកងពលតូចអន្តរគមន៍លេខ១១ ទាំងក្នុងពេលបំពេញបេសកកម្ម នៅសមរភូមិមុខ ក៏ដូចជានៅមូលដ្ឋានក្រោយ ដែលរហូតមកដល់ពេលនេះ អង្គភាព បានទទួលការឧបត្ថម្ភ គិតជាថវិការ គឺ **៣២៩.៦៦៦.៧៥០ រៀល** ដែលក្នុងនោះ គិតក្នុងការចំណាយលើការសាងសង់អគារសិក្សា-ទិញម៉ាស៊ីនបូមទឹក-ស្តាស្រះទឹក-ជីកស្រះថ្មី-ឧបត្ថម្ភម៉ាស៊ីនភ្លើង-រថយន្តផ្ទុក-ទូរទស្សន៍ និងគោ១៩ក្បាល ។ ដោយឡែក ក្រុមហ៊ុន ឡុង ស្រេង ចំការកៅស៊ូបឹងកេត ក៏បានឧបត្ថម្ភ ថវិការចំនួន **៤៧.១៨៧,៦០ ដុល្លា ស.រ.អា** សំរាប់រួមចំណែកអភិវឌ្ឍន៍ ក្នុងអង្គភាពផងដែរ ។ ថ្ងៃនេះអង្គភាព បានទទួលនូវអំណោយថ្មីមួយទៀត គឺត្រាក់ទ័រ ភ្ជួររាស់ដី ០១គ្រឿង ។ លោកឧត្តមសេនីយ៍ ប្រធានកងពលបញ្ជាក់ថាៈអំណោយ ដ៏ថ្លៃថ្លាទាំងនេះ បានផ្តល់នូវកំលាំងចិត្ត កំលាំងស្មារតី និងភាពកក់ក្តៅ ក្នុងភារកិច្ចស្នូលការពារជាតិ មាតុភូមិ និងប្រជាជន។

មានប្រសាសន៍ សំណេះសំណាល នាឱកាសនោះ ឯកឧត្តម **ចម ប្រសិទ្ធ** បានវាយតំលៃខ្ពស់ ចំពោះវីរៈភាពអង់អាចក្លាហាន របស់កងពលអន្តរាគមន៍តូចអន្តរាគមន៍លេខ១១ ក្នុងបុព្វហេតុការពារជាតិ មាតុភូមិ តាំងពីប្រទេសស្ថិតក្នុងភ្លើងសង្គ្រាម រហូតទទួលបានសុខសន្តិភាព ដូចបច្ចុប្បន្ន ។ ជាពិសេស ក្នុងដំណាក់កាលដែលប្រទេសជាតិកំពុងឈានឆ្ពោះទៅការអភិវឌ្ឍន៍ កងពលអន្តរាគមន៍លេខ១១ នៅតែមានភារកិច្ចយ៉ាងមុតស្រួច ក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់ សង្គម ក្នុងមូលដ្ឋាន ជាពិសេស គឺការឈរជើងការពារយ៉ាងរឹងមាំ នៅព្រំដែនទិសព្រះវិហារ និងតំបន់ព្រំដែនដ៏ទៃទៀត ដើម្បីការពារបូរភាពទឹកដី និងអធិបតេយ្យជាតិខ្មែរ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈត្រាក់ទ័រ០១គ្រឿង ដែលមានតំលៃ ១៩.០០០ ដុល្លានេះ គឺបានដោយការជួយឧបត្ថម្ភពីថ្នាក់ដឹកនាំនិងមន្ត្រីក្រោមឱវាទក្រសួងពាណិជ្ជកម្ម សំរាប់សំរួលដល់ការភ្ជួរាស់ដីដាំដំណាំកៅស៊ូ របស់អង្គភាព ក្រោមការជួយឧបត្ថម្ភរបស់ក្រុមហ៊ុនឡុងស្រេង លើផ្ទៃដីចំនួន១០០ ហិចតា ។ ហើយនៅពេលខាងមុខក្រសួងពាណិជ្ជកម្ម ក៏ដូចជាក្រុមហ៊ុន ឡុងស្រេង ចំការកៅស៊ូ បឹងកេត ដែលមានសម្ព័ន្ធភាពរួមគ្នា ជាមួយអង្គភាពកងពល នឹងជួយឧបត្ថម្ភ ជាបន្តទៀត ។

ទន្ទឹមនិងការប្រគល់សោរត្រាក់ទ័រ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានឧបត្ថម្ភ ស្រាបៀ អង្គរ ចំនួន១០០ កេស ទឹកក្រូច ១០០កេស និងបារី ៣០ ប៉ិច សំរាប់កងពលចាត់ចែង ក្នុងឱកាសបុណ្យ ភ្ជុំបិណ្ឌខ្មែរ នាពេលខាងមុខនេះ ដែលជាអំណោយរបស់ក្រុមហ៊ុន ក្នុងស្រុក តាមរយៈឯកឧត្តមផ្ទាល់ ។